# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបុណ្យព្រះយេស៊ូប្រសូតនៅកំពត
# កំពតថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨

*យើងបន្តរួមរស់ជាព្រះសហគមន៍*

| |
|---|
| អត្ថបទទី១៖ ១សម ១,២៤-៣៨ |
| អត្ថបទទី២៖ ១សម ២,១.៤-៨ |
| ដំណឹងល្អ៖ លក ១,៤៦-៥៦ |

បងប្អូនជាទីស្រឡាញ់!

យប់នេះយើងបានស្ដាប់ "**សូមលើកតម្កើង សិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត ហើយសូមឲ្យមនុស្សលោកដ៏ជាទីស្រឡាញ់របស់ព្រះអង្គបានសេចក្ដីសុខសាន្ត**"។ ពាក្យនេះគឺទេវទូតច្រៀងកោតសរសើរព្រះជាម្ចាស់ ដោយសង្ឃឹមមនុស្សទាំងអស់ដែលជាទីស្រឡាញ់របស់ព្រះអង្គបានសេចក្ដីសុខសាន្ត។ មូលហេតុអ្វី នៅក្នុងថ្ងៃដែលប្រារព្ធបុណ្យព្រះយេស៊ូប្រសូតមនុស្សទាំងអស់ទទួលសេចក្ដីសុខសាន្ត? មូលហេតុអ្វីក្រុមទេវទូតកំពុងច្រៀងនៅស្ថានបរមសុខដើម្បីណែនាំឲ្យមនុស្សទាំងអស់ទទួលសេចក្ដីសុខសាន្ត? ដោយសារនៅពេលហ្នឹង យើងកំពុងនឹកឃើញដល់ព្រះកុមារយេស៊ូប្រសូត។ អម្បាញ់មិញនៅពេលយើងបានជុំគ្នានៅជុំវិញរោងព្រះយេស៊ូ យើងបាននឹកឃើញរឿងដែលបានកើតឡើងកាលពី២០០០ឆ្នាំមុន។ នៅក្នុងពិភពលោកទាំងមូល ឆ្នាំសូន្យ គឺឆ្នាំដែលព្រះយេស៊ូប្រសូត។ នៅប្រទេសកម្ពុជាយើងឆ្នាំសូន្យ គឺជាសម័យប៉ុលពត ដែលបំផ្លាញអ្វីៗទាំងអស់ នឹកឃើញដល់ទុក្ខលំបាក ជាពេលវេលាដែលគ្មានសេរីភាព គ្មានសាលា គ្មានផ្សារ។

ឆ្នាំសូន្យរបស់យើងផ្សេង គឺឆ្នាំអស្ចារ្យ ដោយសារមានថ្ងៃហ្នឹងតទៅ យើងដឹងថាមានអ្វីដែលប្លែកនៅផែនដីនេះ។ ជារៀងរាល់ឆ្នាំ យើងជួបជុំគ្នាដើម្បីនឹកឃើញដល់ព្រះយេស៊ូប្រសូត។ ប៉ុន្តែពេលយើងនឹកឃើញព្រះយេស៊ូប្រសូត មិនមែនដូចយើងធ្វើថ្ងៃខួបកំណើតរបស់យើង ប៉ុន្តែយើងពោរពេញដោយអំណរសប្បាយ។ ដោយសារយើងដឹងថា នៅក្នុងឆ្នាំសូន្យហ្នឹង នៅពេលដែលព្រះយេស៊ូបានប្រសូត នៅក្នុងភូមិបេថ្លេហិមដែលជាភូមិមួយតូចណាស់។ ដូច្នេះនៅក្នុងភូមិតូចនេះ មានអ្វីដែលកើតឡើងដ៏អស្ចារ្យ ណែនាំឲ្យក្រុមទេវទូតចុះពីស្ថានបរមសុខ ទេវទូតមានន័យថាតំណាងរបស់ព្រះជាម្ចាស់ ចុះមកដើម្បីច្រៀងឲ្យមនុស្សលោកដ៏ជាទីស្រឡាញ់របស់ព្រះអង្គបានសេចក្ដីសុខសាន្ត។ សេចក្ដីសុខសាន្តចេញពីកុមារយេស៊ូ! កុមាយេស៊ូដ៏តូចនេះមានម្ដាយធម្មតាគឺព្រះនាងម៉ារី យើងឃើញមានឪពុកគឺលោកយ៉ូសែប។ ព្រះនាងម៉ារី និងលោកយ៉ូសែបក៏កំពុងមើល និងឆ្ងល់ដែរ "**កូននេះហេតុអ្វីអស្ចារ្យម្ល៉េះ? មូលហេតុអ្វីគេមកគោរពដូចនេះ?**" ពិតមែនអស្ចារ្យ ដោយសារនៅក្នុងភូមិតូចនិងធម្មតាបំផុត ចេញពីឪពុកម្ដាយដែលជាគ្រួសារធម្មតា យើង

ឃើញព្រះយេស៊ូផ្ទាល់ដែលជាព្រះជាម្ចាស់ ដែលយាងមកដើម្បីណែនាំឲ្យមនុស្សទាំងអស់ពោរពេញដោយសេចក្ដីសុខសាន្ត ដើម្បីណែនាំឲ្យមនុស្សទាំងអស់ ចាប់ពីពេលនោះតទៅ មានន័យថាចាប់ពី២០១៨ឆ្នាំកន្លងមក អាចយល់ថា យើងពោរពេញដោយសេចក្ដីសង្ឃឹម។ មូលហេតុអ្វីយើងមានក្ដីសង្ឃឹម? ព្រះយេស៊ូប្រសូតហើយ ជាការអស្ចារ្យមួយដោយសារជាកូនរបស់ព្រះជាម្ចាស់។ ប៉ុន្តែឲ្យយើងមើលដំណើរជីវិតរបស់ព្រះយេស៊ូ គឺណែនាំឲ្យអ្នកជំងឺជាសះស្បើយ ណែនាំឲ្យអ្នកក្រក្រីមានសេចក្ដីសង្ឃឹម ណែនាំឲ្យកូនក្មេងដែលមិនសូវមានតម្លៃព្រះអង្គស្វាគមន៍គេជានិច្ច។ ប៉ុន្តែចុងក្រោយបំផុត ជីវិតព្រះយេស៊ូបញ្ចប់នៅលើឈើឆ្កាង។ ប្រសិនបើយើងនឹកឃើញថាព្រះយេស៊ូកើតជាកូនក្មេងធម្មតាម្នាក់ នឹកឃើញប៉ុន្មានឆ្នាំដែលព្រះយេស៊ូបានធ្វើការអស្ចារ្យ ដើម្បីណែនាំឲ្យប្រជាជនមានសេចក្ដីសង្ឃឹម នឹកឃើញដល់ថ្ងៃចុងក្រោយរបស់ព្រះយេស៊ូនៅលើឈើឆ្កាង។ ប៉ុន្តែថ្ងៃនេះយើងជួបជុំគ្នា មិនមែនដោយសារព្រះយេស៊ូសោយទិវង្គតនៅលើឈើឆ្កាង គឺដោយសារព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។

ដូច្នេះថ្ងៃនេះ យើងគោរពបុណ្យព្រះយេស៊ូប្រសូត យើងនឹកឃើញទាំងអស់ គឺព្រះយេស៊ូដែលប្រសូត ព្រះយេស៊ូដែលមានជីវិតនៅក្នុងភូមិណាសារ៉ែត ព្រះយេស៊ូដែលចាប់ផ្ដើមប្រមូលអ្នកតូចតាចដែលអស់សង្ឃឹមពេលមានជីវិត ព្រះយេស៊ូដែលសោយទិវង្គត ប៉ុន្តែមានព្រះជន្មរស់ឡើងវិញ។ នេះជាមូលហេតុថ្ងៃនេះយើងជុំគ្នា ជាមូលហេតុថ្ងៃនេះយើងមិនធ្វើខួបកំណើតធម្មតាទេ ដោយសារយើងមិនត្រឹមតែនឹកឃើញព្រះយេស៊ូកាលពីជាង២០០០ឆ្នាំមុន ប៉ុន្តែយើងនឹកឃើញដល់ព្រះយេស៊ូដែលមានជីវិតថ្ងៃនេះជាមួយយើង។ អម្បាញ់មិញ នៅមុខរោងព្រះយេស៊ូយើងបានប្រកាសថា ពិតមែនយើងមើលព្រះកុមារយេស៊ូ ប៉ុន្តែយើងមើលព្រះយេស៊ូនៅក្នុងព្រះពន្លា ដោយសារថ្ងៃនេះព្រះយេស៊ូមានជីវិតនៅក្នុងខ្ញុំ (នៅជាមួយខ្ញុំ) និងថ្ងៃនេះព្រះយេស៊ូណែនាំឲ្យខ្ញុំពោរពេញដោយសេចក្ដីសុខសាន្ត និងអាចច្រៀងកោតសរសើរព្រះជាម្ចាស់យ៉ាងអស់ពីដួងចិត្តរួមជាមួយទេវទូត ដោយសារខ្ញុំដឹងថាខ្ញុំដើរតាមជីវិត ខ្ញុំដើរតាមពន្លឺ ខ្ញុំដើរតាមសេចក្ដីសង្ឃឹម។ ២០០០ឆ្នាំជាង ដែលមនុស្សដើរតាមព្រះយេស៊ូ ២០០០ឆ្នាំទៀតដែលព្រះយេស៊ូណែនាំឲ្យមនុស្សពោរពេញដោយសេចក្ដីសង្ឃឹម។

ព្រឹកមិញយើងបានជួបជុំគ្នាជាមួយកូនក្មេងសាលាមត្តេយ្យ និងបឋមសិក្សា ជាមួយឪពុកម្ដាយ យើងឃើញកូនក្មេងបានសម្ដែងរឿងព្រះយេស៊ូប្រសូត។ ពួកគេមិនមែនជាគ្រីស្ដបរិស័ទ ប៉ុន្តែបានសម្ដែងអំពីសេចក្ដីសង្ឃឹមមួយ។ ដោយសារយើងមានព្រះយេស៊ូនៅទីនេះ យើងបានបង្កើតសាលាដូចបច្ចុប្បន្ន ដោយសារយើងមានជំនឿលើព្រះយេស៊ូនៅទីនេះ យើងមានកម្លាំងដើម្បីទទួលស្វាគមន៍ក្មេង និងឲ្យពួកគេមានសេចក្ដីសង្ឃឹមដ៏ពេញលក្ខណៈ។ ថ្ងៃនេះ យើងមាន

យុវជនយុវនារីដែលមកពីផុះគិរី មកពីកោះស្លា មកពីត្រពាំងល្ពៅ យើងមកពីត្រពាំងរុន យើងមកពីព្រែកប្រស់ យើងមកពីមណ្ឌលកំពត-កែបនេះ យើងមកពីគ្រប់ទីកន្លែងដែលយើងនៅ។ ប៉ុន្មានឆ្នាំហើយដែលយើងមាន សាលាមត្តេយ្យ កម្មវិធីមេត្តាករុណា យើងលើកទឹកចិត្តអ្នកជំងឺ យើងណែនាំឲ្យអ្នកក្រក្រីមានសេចក្ដីសង្ឃឹមថែមទៀត យើងទទួលកូនក្មេងពិការ យើងទទួលអ្នកជំងឺអេដស៍ យើងមានសកម្មភាពច្រើនណាស់។ យើងធ្វើបានដោយសារយើងជឿថា ព្រះយេស៊ូចាប់កំណើតជាមនុស្ស ព្រះយេស៊ូសោយទិវង្គត ប៉ុន្តែព្រះយេស៊ូថ្ងៃនេះគង់នៅជាមួយយើង។

ថ្ងៃនេះ គឺដើម្បីនឹកឃើញវត្តមានរបស់ព្រះយេស៊ូនៅក្នុងពិភពលោកនេះ ដែលកំពុងណែនាំយើងឲ្យយើងធ្វើការអស្ចារ្យតាមរបៀបព្រះយេស៊ូតែម្តង។ ដូច្នេះថ្ងៃនេះយើងមានកម្លាំងណាស់ដើម្បីបន្តទទួលកូនក្មេង បន្តណែនាំឲ្យអ្នកជំងឺទៅមន្ទីរពេទ្យ បន្តយកចិត្តទុកដាក់ជាមួយអ្នកក្រីក្រ បន្តយកចិត្តទុកដាក់ជាមួយមនុស្សដែលគ្មានទីពឹង ដើម្បីណែនាំឲ្យគេមានសេចក្ដីសង្ឃឹម។ ម្សិលមិញយើងសម្ពោធសាលាមត្តេយ្យមួយនៅភូមិសុខសាន្ត ពេលយើងហូបបាយយើងមានកូនក្មេងមត្តេយ្យ យើងមានឪពុកម្តាយ យើងមានកូនក្មេងពិការមួយចំនួន យើងមានឪពុកម្តាយគេទៀត យើងមានប្រជាជនធម្មតា យើងមានរដ្ឋមន្ត្រីដែលចូលជាមួយយើង។ តាមពិតពេលយើងចូលថ្ងៃនេះ នៅពេលគេមកថ្វាយបង្គំព្រះយេស៊ូ មានគ្រូគង្វាល ជាមនុស្សដែលនៅសម័យហ្នឹងគេអត់ទុកចិត្ត យើងមានហោរាចារ្យ ដែលជាអ្នកដែលមានចំណេះដឹងមានលុយ មានសមត្ថភាព យើងមានប្រជាជនធម្មតា យើងមានគ្រប់ឋានៈគ្រប់វណ្ណៈនៅក្នុងសង្គម ដែលមករកព្រះយេស៊ូក្នុងមហាគ្រួសារតែមួយ។ នៅពេលនោះជាង២០០០ឆ្នាំមុន ពេលហោរាចារ្យដែលទៅថ្វាយបង្គំ គេមិនខ្លាចទៅថ្វាយបង្គំនៅកន្លែងមួយមិនគួរសម ដោយសារព្រះយេស៊ូបានប្រសូតនៅក្រោលគោ ដែលមានអាចម៍គោ។ កន្លែងហ្នឹង ហោរាចារ្យដែលជាអ្នកមាន ដែលជាអ្នកមានឋានៈខ្ពស់ គេទៅថ្វាយបង្គំនៅកន្លែងហ្នឹងគេមិនគិតអ្វីសោះ ប្រជាជនក៏មកដែរ គេអត់ខ្លាចអ្វីទេ។ ទាំងអស់គ្នាគេលែងនឹកឃើញ មានអ្នកធំ មានអ្នកតូច មានអ្នកអាក្រក់ មានអ្នកល្អ មានអ្នកសុចរិតមានអ្នកទុច្ចរិត ទាំងអស់ ជួបជុំគ្នានៅក្នុងមហាគ្រួសារតែមួយ។

ខ្ញុំសូមអធិដ្ឋាន ដើម្បីឲ្យយើងទាំងអស់ដែលជាព្រះសហគមន៍នៅប្រទេសកម្ពុជា ជាពិសេសនៅភូមិភាគភ្នំពេញ ជាពិសេសនៅមណ្ឌលសកម្មភាពកំពត-កែប ឲ្យយើងពោរពេញដោយអំណរសប្បាយ។ ដោយនឹកឃើញដល់ព្រះសហគមន៍កាតូលិករបស់យើង ទោះបីជាព្រះសហគមន៍តូចតាចក៏ដោយ នេះមិនសំខាន់ទេ ដោយសារព្រះយេស៊ូចាប់កំណើតជាមនុស្សនៅក្នុងកន្លែងតូចមែនទែន ប៉ុន្តែព្រះយេស៊ូមានឥទ្ធិពលលើពិភពលោក។ ដូច្នេះសូមឲ្យព្រះសហគមន៍តូចតាចរបស់យើង និងគ្រប់ទីកន្លែងដែលយើងរស់នៅ សូមយកចិត្តទុកដាក់ដើម្បីណែនាំទាំង

សេចក្ដីស្រឡាញ់ ទាំងមេត្តាករុណា ទាំងការលើកទឹកចិត្តដែលព្រះយេស៊ូប្រទានឲ្យយើងដល់បងប្អូនទាំងអស់។ យើងបន្តនៅក្នុងជំនឿ នៅក្នុងសេចក្ដីក្លាហាន ដោយសារព្រះសហាគមន៍របស់យើងតូច ដែលមានក្រុមមេត្តាករុណា ដែលមានសាលា ដែលណែនាំឲ្យមនុស្សច្រើនយល់ថាជីវិតខ្ញុំមានតម្លៃណាស់។ ដូចគ្រូគង្វាល ពេលគេមកថ្វាយបង្គំណែនាំឲ្យគេយល់ថាជីវិតគេមានតម្លៃណាស់ ដោយសារប្រជាជនផ្សេងៗគេមើលងាយ ប៉ុន្តែព្រះយេស៊ូស្វាគមន៍គេ។ ជីវិតរបស់ព្រះយេស៊ូ ស្វាគមន៍មនុស្សទាំងអស់ដើម្បីបង្កើតគ្រួសារដ៏សុខសាន្ត។ នៅក្នុងឆ្នាំគ្រួសារនេះ ឲ្យយើងបន្តរួមរស់ជាព្រះសហាគមន៍ ជាមហាគ្រួសារតែមួយដែលចេះរួមរស់ជាមួយគ្នា ដោយសម្ដែងធម៌មេត្តាករុណា ដែលចេញពីព្រះជាម្ចាស់ផ្ទាល់។

**អបអរសាទរបុណ្យព្រះយេស៊ូប្រសូត! អាម៉ែន៕**